**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀង រវាងនាយកក្រុមហ៊ុន ឈុន ឌីង ព្រីនធីង ខូអិលធីឌី ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃពីរ ខែកញ្ញា ថ្ងៃទីពីរ វេលាម៉ោងដប់បួនគត់ នៅការិយាល័យក្រុមហ៊ុន **ឈុនឌីង ព្រីនធីង ខូអិលធីឌី** មានកិច្ចប្រជុំពិភាក្សា រវាងនាយកក្រុមហ៊ុន ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុនស្តីពីការព្យួរកិច្ចសន្យាការងារក្រោយពីបានពិភាក្សាគ្នារួចមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម ៖

១.បច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតចំនួន ២៧នាក់ (ស្រី១៥នាក់)ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២០៣នាក់ (ស្រី១១២នាក់) រយៈពេល ៦១ថ្ងៃ ដោយគីតចាប់ពីថ្ងៃទី១៦ ខែ កញ្ញា ឆ្នាំ២០២២ រហូត ដល់ថ្ងៃទី១៥ ខែ វិច្ឆិកា ឆ្នាំ២០២២ ។

២.ភាគីទាំងពីរយល់ព្រមទទួលយក និងផ្តល់ប្រាក់ឧបត្ថមចំនួន ៥០ ដុល្លាអាមេរិក សម្រាប់កម្មករម្នាក់ៗ ក្នុងរយៈ ពេលព្យួរការងារនេះ ។

៣.ក្នុងករណីបងប្អូនកម្មករ មិនបានចូលធ្វើការវិញតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

ប្រាក់ឧបត្ថមក្នុងកំឡុងពេលព្យួរកិច្ចសន្យានេះនិងបើកជូនបងប្អូនកម្មករនៅថ្ងៃទី១០នៅខែបន្ទាប់។ អង្គប្រជុំបានចប់នៅវេលាម៉ោង១៤ និង៤០នាទី រសៀល នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃសុក្រ ៧កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី 2 ខែ កញ្ញា ឆ្នាំ2022
នាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឈុន ឌីង ព្រីនធីង ខូ អិលធីឌី
QUN DING PRINTING Co., Ltd
KINGDOM OF CAMBODIA

CHEN YEN MING

ស្នាមមេដៃសហជីព

ឡូញ គុន

ស៊ីថា ប៊ុនថាន់

អ៊ុន ដា

ស្នាមមេដៃតំណាងកម្មករនិយោជិត

ស៊ីថា ប៊ុនថាន់

អ៊ុន ដា

សាត់ ផាត់ណា